# រឿង ដំណើរទៅព្រៃក្រមុំ



# រឿង ដំណើរទៅព្រក្រហ្មំ



គូរដោយ គីម សុគន្ធ

បោះពុម្ពផ្សាយដោយអង្គការសន្តិស៊ើត្រចិត្ត (SVA)

ព្រឹកមួយ ឧសានិងឪពុកបានចេញទៅរកដើមថ្នាំនៅក្នុងព្រៃ ។ ឧសាសប្បាយចិត្តណាស់ដោយបានចេញទៅព្រៃ។



“ពុក! ខ្ញុំចង់ធ្វើជាគ្រូថ្នាំបុរាណដូចពុកណាស់ ” ។ ឧសានិយាយទៅកាន់ឪពុក ។ ឪពុកតបវិញថា “ ពុកក៏គិតអ៊ីចឹងដែរ ព្រោះយើងអាចជួយសង្គ្រោះអ្នកភូមិបាន ។ ដូច្នេះ កូនត្រូវស្គាល់ដើមថ្នាំទាំងអស់ជាមុនសិន ប៉ុន្តែសព្វថ្ងៃនេះ ដោយសារការកាប់បំផ្លាញព្រៃឈើ ដើមថ្នាំក៏កាន់តែខ្សត់ទៅដែរ ”។ ឪពុកហុចពូថៅមួយទៅអោយឧសាហើយនិយាយប្រាប់ : “ ណេះ ចាប់ផ្តើមទៅ! កូនមិនត្រូវទៅឆ្ងាយពីពុកពេកទេ ។ បើកូនវង្វេងផ្លូវ ចូរកូនដើរឆ្ពោះទៅទិសខាងកើត កូននឹងបានទៅដល់ភូមិយើងហើយ ” ។



ថ្ងៃនេះ ជាលើកទីមួយហើយដែលឧសាបានហាត់រៀនដើររុករកដើមថ្នាំនៅក្នុងព្រៃ ។ ព្រៃដែលមានតែដើមឈើទាបៗ សំបូរតែបន្លារសេមរសាម ធ្វើអោយឧសាពិបាកដើរ និងក្តៅសឹងទ្រាំពុំបាន ។ ពេលនោះ ឧសាឮសម្លេងយំ "ប៊ីត ៗ ៗ. . . " វាក៏ដើរសំដៅទៅ ស្រាប់តែឃើញកូនឈ្លូសមួយឈរនៅជិតមេវាដែលដេកស្មៀមឥតកំរើក ។



កូនឈ្លូសបានយកក្បាលទៅអង្រួនមេវា តែមេឈ្លូសនៅតែមិនកំរើកដដែល ។ ឧសាស្ទាបខ្លួនមេឈ្លូសមើល ហើយនិយាយថា " អត់ប្រយោជន៍ទេ! ម៉ែឯងបានស្លាប់ទៅហើយ " ។ កូនឈ្លូសសម្លឹងមុខឧសាទាំងទឹកភ្នែក ។ ឧសានិយាយលួងលោមកូនឈ្លូសថា "ឈប់យំទៅ! ព្រៃនេះហាក់មិនមានអ្វីអាចអោយឯងរស់នៅបានតទៅទៀតទេ ។ ឯងនឹងស្លាប់ដូចម៉ែឯងដោយគ្មានចំណីអាហារ និងទឹកផឹក ។ ឯងក៏មិនអាចរស់នៅតែម្នាក់ឯងបានដែរ ឯងត្រូវទៅជួបជុំបងប្អូន ចាំខ្ញុំជូនឯងទៅ " ។





កូនឈ្លូសងក់ក្បាល ហើយមុននឹង
ចាកចេញទៅ វាងាកសម្លឹងមេវាទាំង
ទឹកមុខស្រងូតស្រងាត់ ។ ឧសាបាននាំ
កូនឈ្លូសធ្វើដំណើររហូតដល់ព្រះអាទិត្យ
នៅចំពីលើក្បាល ទើបមកដល់បឹងធំ
មួយដែលរីងទឹកអស់ គឺបឹងនោះហើយ
ដែលគ្រួសារឈ្លូស និងសត្វឯទៀត
តែងតែមកផឹកទឹកនៅទីនេះ ។

មានត្មាតមួយគូទុំលើមែកឈើងាប់ ក្បែរមាត់បឹង ស្រែកឡើងថា «អ៊ូ! គឺអាល្អិតឯងទេតើ!»។ កូនឈ្លូសត្រេកអរណាស់សួរទៅត្មាតថា «លោកតា លោកយាយបានឃើញបងប្អូនខ្ញុំឬទេ?»។ ត្មាតឆ្លើយថា «ឃើញ! តែពួកគេលែងមកទីនេះទៀតហើយ»។ កូនឈ្លូសសួរទៅត្មាតទាំងក្រៀមក្រំថា «លោកតា លោកយាយដឹងថាពួកគាត់ទៅណាទេ?»។ ត្មាតឆ្លើយថា «ទៅព្រៃក្រមុំ»។ កូនឈ្លូសងក់ក្បាល និងជ្រុំជើងយ៉ាងញាប់ ហើយនិយាយថា «អរគុណ លោកតា លោកយាយណាស់! ខ្ញុំលាសិនហើយ»។





ឧសា និងកូនឈ្លូសនាំគ្នាបន្តដំណើរទៅមុខទៀត ។ ពេលនោះ ព្រះអាទិត្យហៀបនឹងលិច នៅក្នុងព្រៃមានភាពងងឹតបន្តិចម្តងៗ។ ឧសា និងកូនឈ្លូសឮសូរសន្ធឹកព្រឹបៗ ព្រូសប្រាស់ប្រាវៗ និងសម្លេងវូមៗពីព្រៃម្ខាង ។ ឧសា និងកូនឈ្លូសភ័យណាស់ រត់ទៅពួនក្នុងគុម្ពោតព្រៃមួយ ។ ស្រាប់តែឃើញដំរីមួយហ្វូងដើរចេញមក ។ ត្រេកអរណាស់ កូនឈ្លូសស្ទុះទៅស្កាត់ដំណើរដំរី ហើយនិយាយថា "ជំរាបសួរ លោកតា លោកអ៊ំនាំគ្នាទៅណា? មានឃើញបងប្អូនខ្ញុំឬទេ?"។ ដំរីធំជាងគេឆ្លើយថា "ល្អហើយ អានាងតូច! យើងមិនបានឃើញបងប្អូនឯងទេ ។ ឥឡូវយើងនាំបងប្អូន កូនចៅទៅរស់នៅកន្លែងថ្មី ឯព្រៃក្រមុំ"។ ថាហើយ ពួកដំរីក៏បន្តដំណើរទៅទៀត ។



ឧសា និងកូនឈ្លូសធ្វើដំណើរទៅមុខទៀតតាមក្រោយហ្វូងដំរី ។ កូនឈ្លូសអស់កម្លាំងទន់ជើងទៅមុខទៀតលែងរួច ។ ឧសាអង្អែលក្បាលកូនឈ្លូស ហើយនិយាយថា « ខំបន្តិចទៀតទៅអ្នកតូច! យើងត្រូវទៅអោយដល់ព្រៃក្រមុំ មុនពេលយប់ងងឹត » ។ ឈ្លូសតូចធ្វើភ្នែកភ្លឹះៗ ហើយប្រឹងក្រោកដើរតទៅមុខទៀត ។



ឧសា និងកូនឈ្លូសដើរទៅមុខដោយសេចក្ដីក្លាហាន ។ ពួកគេទាំងពីរខំដើរតាមដានជើងដំរី ដោយស្ងាត់ៗ ។ យប់កាន់តែងងឹតទៅៗ ត្រជាក់ទៅៗ ។





លុះមកដល់កន្លែងមួយ ឧសាទះខ្នងកូនឈ្លូសតិចៗ ហើយនិយាយថា “ឈប់! កុំអាលទៅទៀត នៅខាងមុខមានអ្វីភ្លឺព្រាលៗ រាងច្រងេងច្រងាងដូចមនុស្សធំខ្ពស់ ” ។ ប៉ុន្តែ កូនឈ្លូសមិនឆ្លើយតប ហើយរត់យ៉ាងសប្បាយទៅរកពន្លឺនោះ ។ បន្ទាប់មក វាធ្វើសម្លេងប៊ឺតៗអោយឧសាចូលទៅ ។ ឧសាដើរចូលទៅទាំងងឿងឆ្ងល់ ។ ឧសាឃើញហើយនិយាយថា “អូ៎ នេះជាតិផ្សូរដែលជាប់នឹងសំបកដើមឈើងាប់ទេតើ ! ឯងឃើញទេ វាភ្លឺល្អណាស់ ”។



ពីក្នុងព្រៃមានអំពិលអំពែកជាច្រើនភ្លឺភ្លឹបភ្លែតៗ អណ្តែតចេញមកថែមទៀត ។ ឧសានិយាយប្រាប់កូនឈ្លូសថា "នៅទីនេះ សប្បាយមែន! មើលចុះដូចជាពិធីបុណ្យមួយនៅភូមិខ្ញុំដែរ "។ អំពិលអំពែកទាំងនោះបានអណ្តែតមកជិតកូនឈ្លូស ។ កូនឈ្លូសស្រែកដោយរីករាយថា "រាត្រីសួស្តី បងៗ!" ។ អំពិលអំពែកតបវិញ អូ៎ គឺបងទេ ! "រាត្រីសួស្តី! តើបងអញ្ជើញទៅណាទាំងយប់ងងឹតដូច្នេះ?" ។ កូនឈ្លូសឆ្លើយថា " ខ្ញុំទៅព្រៃក្រមុំរកបងប្អូន ។ តើបងៗបានឃើញពួកគាត់ឬទេ?" ។ អំពិលអំពែកប្រាប់ថា " ទីនេះ ជាព្រៃក្រមុំហើយ! បងប្អូនរបស់បងនៅខាងមុខឯណោះ " ។



ឧសា និងកូនឈ្លូសក៏ដើរទៅមុខទៀត ។ មួយរំពេចនោះ ស្រាប់តែអ្នកទាំងពីរឮសូរសន្ធឹកខ្ទ័រព្រៃ ។ ឧសាភ័យណាស់ បិទភ្នែក ហើយឱនចុះ ។ បន្តិចមក សម្លេងនោះក៏ស្ងប់ស្ងាត់ទៅ ។ ឧសាបើកភ្នែកឡើងវិញ ឃើញហ្វូងឈ្លូស ហ្វូងដំរី ហ្វូងខ្លាព្រៃ និងអំពិលអំពែកនៅពីមុខគេ ។ ទាំងអស់គ្នាសម្លឹងឧសាយ៉ាងស្ងៀមស្ងាត់ ។ ឧសានិយាយទៅកាន់ហ្វូងឈ្លូសថា " ខ្ញុំសូមប្រគល់ប្អូនអ្នកទៅអោយអ្នកវិញហើយ សូមអ្នកទទួលយកចុះ " ។



ឧសាបែរខ្លួនបម្រុងត្រឡប់មកក្រោយវិញ តែពេលនោះ នៅក្នុងព្រៃមានពន្លឺភ្លើងគប់ពីរតម្រង់មក ព្រមជាមួយនឹងសម្រែកស្រែកថា "ឧសាអើយ! ឧសា!... "។ ឧសាបែរទៅនិយាយជាមួយសត្វទាំងអស់ថា "ឪពុកខ្ញុំមករកខ្ញុំហើយ "។ សត្វទាំងអស់ឈរសម្លឹងមកឧសាដោយសេចក្តីរំភើប ។



ឧសាដើរតម្រង់ពន្លឺភ្លើងគប់ ហើយស្រែកថា “ពុក! ពុកអើយ! ខ្ញុំនៅឯណេះ!” ។ ឪពុកឧសា និងបងប្រុសវាបានរត់សំដៅមក ។ ឪពុកស្រវាឱបកូន ហើយនិយាយ “បើពុកមិនបង្រៀនកូនអោយចេះរកដើមថ្នាំ កូនប្រហែលជាមិនមកទីនេះទេ ។ សំណាងណាស់ដែលពុករកឯងឃើញ” ។



សត្វទាំងអស់និយាយថា “ពួកយើងក៏បានជួបជុំបងប្អូនវិញដែរ សូមអរគុណអ្នកទាំងអស់គ្នា ។ សូមជំរាបលា” ។



ក្រោយពេលត្រឡប់មកផ្ទះ ឧសាតែងនឹកឃើញដល់កូនឈ្លូស ត្មាត ហ្វូងដឺរ ហ្វូងឆ្កែព្រៃ និងអំពិលអំពែក ដែលនៅក្នុងព្រៃក្រមុំដ៏មានពន្លឺយ៉ាងល្អចម្លែកនៅពេលយប់ ៕

**ចប់**



# រឿង ដំណើរទៅព្រៃក្រមុំ

និពន្ធដោយ លោក វ៉ា សំអាត
គូររូបដោយ លោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្មៃគ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០០៤

